**សំណួរ ពាក់ព័ន្ធនឹងច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣** (៣)
**តើច្បាប់រដ្ឋធម្មនុញ្ញ មានចែងអ្វីខ្លះអំពីសិទ្ធិពាក់ព័ន្ធនឹងយុត្តិធម៌ព្រហ្មទណ្ឌ** (Criminal Justice)?

**<u>ចម្លើយ</u>**

កតិកាសញ្ញា ស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ ឆ្នាំ ១៩៦៧ បានចែងអំពីសិទ្ធិពាក់ព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសក្នុងមាត្រា ១៤ និងដោយមាត្រាមួយចំនួនទៀតដូចជា មាត្រា ៦ (សិទ្ធិរស់រានមានជីវិត) មាត្រា ៧ (សិទ្ធិរួចផុតពីអំពើទារុណកម្ម) មាត្រា ៩ (សិទ្ធិទទួលបានការពិនិត្យដោយតុលាការលើភាពស្របច្បាប់នៃការឃាត់ខ្លួន ឬ ឃុំខ្លួន) និងមាត្រា ១០ (ការប្រព្រឹត្តក្នុងអំឡុងជាប់ឃុំឃាំង) ជាដើម។

ក្នុងជំពូកទី ៣ នៃច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ក្នុងចំណោម ២០ មាត្រា ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស មានមាត្រា ចំនួន២ ពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ គឺមាត្រា ៣២ និង ៣៨។ មាត្រា ៣២ ចែងរួម អំពីសិទ្ធិសេរីភាពបុគ្គល រាប់ទាំងការលុបបំបាត់នូវទោសប្រហារជីវិត។ មាត្រា ៣៨ លំអិតបន្ថែមជាច្រើនចំណុចៈ **ទី១**. ការចោទប្រកាន់ ឃាត់ខ្លួន ...ត្រូវអនុលោមតាមច្បាប់។ **ទី ២**. អ្នកត្រូវបានចាប់ខ្លួន (ជនសង្ស័យ) ត្រូវបានចាត់ថា មិនទាន់មានទោស (presumption of innocence)។ **ទី៣**. ក្នុងន័យនេះ មិនត្រូវបានការបំពារបំពានលើរូបរាងកាយ ក្នុងគោលបំណងយកចម្លើយសារភាពទេ។ ចម្លើយប្រភេទនេះ នឹងមិនជាភស្តុតាង នៃពិរុទ្ធភាពឡើយ។ **ទី៤**.នៅក្នុងអំឡុងពេលជាប់ឃុំឃាំង ការបង្ខិតបង្ខំ ឬទណ្ឌកម្មលើរូបរាងកាយ ដែលបន្ថែមទម្ងន់ឈើចាប់ ត្រូវហាមឃាត់។ បុគ្គលជាជនសង្ស័យ មានសិទ្ធិទទួលបានការការពារខ្លួន តាមយន្តការតុលាការ។ ជាចុងក្រោយ ក្រោយពេលពិចារណាភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ករណីមានមន្ទិលថា ជនល្មើសបានប្រព្រឹត្តិ ឬមិនបាន មន្ទិលនឹងត្រូវបានជាប្រយោជន៍នៃជនសង្ស័យ។

**<u>កំណត់សំគាល់</u>**ៈ ជនដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ក្នុងការធ្វើបាបរូបរាងកាយ ត្រូវទទួលទោសតាមច្បាប់ (ក្រមព្រហ្មទណ្ឌ)។ សម្រាប់អត្ថន័យ "មន្ទិលបានប្រយោជន៍ដល់ជនសង្ស័យ" សូមមើលខ្លឹមសារសង្ខេប សេចក្តីសម្រេច លើបណ្តឹងសាទុក្ខបន្ទាន់ ដោយ **ខៀវ សំផន។**

**<u>មាត្រា ៣៨.-</u>**ៈ ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិតកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនចាប់ឃុំឃាំង ឬចាប់ពន្ធនាគារត្រូវហាមឃាត់មិនធ្វើឡើយ ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំ តាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនចាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។